WILL of GOD

316

# តើខ្ញុំស្គាល់ព្រះហឫទ័យព្រះយ៉ាងដូចម្ដេច?

*«កុំឲ្យត្រាប់តាមសម័យនេះឡើយ ចូរឲ្យអ្នករាល់គ្នាបានផ្លាស់ប្រែវិញ ដោយគំនិតបានកែជាថ្មីឡើង ដើម្បីនឹងអាចលមើលឲ្យបានស្គាល់បំណងព្រះហឫទ័យនៃព្រះដែលល្អ ស្រួលទទួល ហើយគ្រប់លក្ខណ៍ផង»* (រ៉ូម ១២:២។)

ការស្គាល់ និងធ្វើតាមព្រះហឫទ័យរបស់ព្រះគឺពិតជាសំខាន់ណាស់។ សូមធ្វើដូចជាព្រះយេស៊ូវ។ ព្រះអង្គមានបន្ទូលថា ព្រះអង្គយាងមកផែនដី *«...មិនមែននឹងធ្វើតាមចិត្តខ្ញុំទេ គឺតាមបំណងព្រះហឫទ័យនៃព្រះវិញ ដែលទ្រង់ចាត់ឲ្យខ្ញុំមក»* យ៉ូហាន ៦:៣៨។ ព្រះហឫទ័យរបស់ព្រះភាគច្រើនត្រូវបានអនុវត្តលើអ្នកជឿគ្រប់រូបដូចគ្នាដែរ។ ប៉ុន្តែ ព្រះមានព្រះហឫទ័យសម្រាប់អ្នកជឿម្នាក់ៗដែលព្រះអង្គបានបង្ហាញបន្តិចម្ដងៗថា នៅពេលអ្នករស់នៅក្នុងការដើរជាមួយទ្រង់នៅក្នុងភាពស្មោះត្រង់ជារៀងរាល់ថ្ងៃ។ អ្នកអាចស្គាល់ព្រះហឫទ័យរបស់ព្រះបាន។ ព្រះអង្គនឹងប្រទានឱ្យអ្នកបានយល់។ *«ចូរទីពឹងដល់ព្រះយេហូវ៉ាឲ្យអស់អំពីចិត្ត កុំឲ្យពឹងផ្អែកលើយោបល់របស់ខ្លួនឡើយ ៦ត្រូវឲ្យទទួលស្គាល់ទ្រង់នៅគ្រប់ទាំងផ្លូវឯងចុះ នោះទ្រង់នឹងដំរង់អស់ទាំងផ្លូវច្រករបស់ឯង»* សុភាសិត ៣:៥-៦។ អ្នកស្គាល់ពីព្រះហឫទ័យទូទៅសម្រាប់អ្នកជឿគ្រប់រូបចេញពីព្រះគម្ពីរ។ អ្នកស្គាល់ព្រះហឫទ័យផ្ទាល់ខ្លួនរបស់ទ្រង់ថាជាព្រះហឫទ័យដែលមិនផ្ទុយពីព្រះបន្ទូលរបស់ទ្រង់ឡើយ ហើយមានជីវិតដែលស្ដាប់បង្គាប់យ៉ាងស្មោះត្រង់។ ចេញពីមូលដ្ឋាននៃការស្ដាប់បង្គាប់ព្រះ អ្នកអាចកំណត់ និងស្ដាប់តាមព្រះឫទ័យរបស់ព្រះសម្រាប់អ្នក។ ចូរសូមបិតារបស់អ្នក។ ទទួលយកការណែនាំចេញពីព្រះបន្ទូល ប្រាជ្ញា ប្រជារាស្ត្រ និងសេចក្ដីសុខសាន្តរបស់ទ្រង់។ នៅពេលអ្នកស្គាល់ព្រះហឫទ័យរបស់ព្រះ ហើយ ស្ដាប់តាមទ្រង់។

**ព្រះហឫទ័យទូទៅរបស់ព្រះ។** ព្រះហឫទ័យរបស់ព្រះភាគច្រើនត្រូវបានរកឃើញនៅក្នុងសេចក្ដីបញ្ញត្តិ គោលការណ៍ និងឧទាហរណ៍ផ្សេងៗនៅក្នុងព្រះគម្ពីរ។ ព្រះគម្ពីរគឺជាប្រភពចម្បងសម្រាប់ការស្គាល់ព្រះហឫទ័យរបស់ព្រះសម្រាប់ជីវិតរបស់អ្នក។ *«ព្រះបន្ទូលនៃទ្រង់ជាចង្កៀងដល់ជើងទូលបង្គំ ហើយជាពន្លឺបំភ្លឺផ្លូវរបស់ទូលបង្គំផង»* ទំនុកតម្កើង ១១៩:១០៥។

១. សេចក្ដីបញ្ញត្តិ។ មានសេចក្ដីបញ្ញត្តិជាច្រើននៅក្នុងព្រះគម្ពីរសម្រាប់អ្នកជឿគ្រប់រូបដូចជា *«ចូរអរសប្បាយជានិច្ច ចូរអធិស្ឋានឥតឈប់ឈរ ចូរអរព្រះគុណក្នុងគ្រប់ការទាំងអស់ ពីព្រោះព្រះទ្រង់សព្វព្រះហឫទ័យឲ្យអ្នករាល់គ្នាធ្វើយ៉ាងដូច្នោះ ដោយនូវព្រះគ្រីស្ទយេស៊ូ»* ១ ថែស្សាឡូនិច ៥:១៦-១៨។ ព្រះយេស៊ូវមានបន្ទូលថា *«បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តរបស់ខ្ញុំចុះ»* យ៉ូហាន ១៤:១៥។ សូមយល់ពីបរិបទនៃសេចក្ដីបញ្ញត្តិរបស់ព្រះ។ ព្រះបានប្រាប់លោកណូអេឱ្យសង់ទូកធំ លោកុប្បត្តិ ៦:១៤។ ព្រះមិនបានប្រាប់អ្នកឱ្យធ្វើដូច្នោះទេ។ ព្រះបានប្រាប់ដាវីឌឱ្យទៅក្រុងហេប្រុន ២ សាំយូអែល ២:១។ ព្រះមិនបានប្រាប់អ្នកឱ្យធ្វើដូច្នោះទេ។ សូមកុំទទួលយកសេចក្ដីបញ្ញត្តិចេញពីបរិបទរបស់ទាំងនេះឡើយ។

២. គោលការណ៍។ មានគោលការណ៍នៅក្នុងព្រះគម្ពីរសម្រាប់អ្នកឱ្យបានកាន់តាម។ គោលការណ៍នៃការគ្រប់គ្រងដ៏ល្អគឺនៅក្នុង លូកា ១៦:១-១៣។ ការបង់ថ្លៃនៃភាពជាសិស្សគឺនៅចុងបញ្ចប់នៃលូកា១៤។ គោលការណ៍នៃស្វែងរកមនុស្សបាត់បង់គឺនៅក្នុងពាក្យប្រៀបធៀបទាំងបីនៅក្នុងលូកា១៥។ សូមធ្វើតាមការទាំងនេះ និងគោលការណ៍ផ្សេងទៀតនៅក្នុងព្រះគម្ពីរ។

៣. ឧទាហរណ៍។ សេចក្ដីបញ្ញត្តិ និងគោលការណ៍របស់ព្រះគម្ពីរផ្ដល់ឱ្យអ្នកនូវព្រះហឫទ័យទូទៅរបស់ព្រះសម្រាប់ជីវិតរបស់អ្នក។ ព្រះគម្ពីរមានផ្ទុកដោយគំរូជាច្រើនសម្រាប់យើងឱ្យដើរតាម។ គំរូដ៏ល្អបំផុតគឺជីវិតរបស់ព្រះយេស៊ូវ។ បន្ទាប់ពីបានលាងជើងរបស់ពួកសិស្សហើយ ព្រះយេស៊ូវមានបន្ទូលថា *«ដ្បិតខ្ញុំបានធ្វើជំរាប់ទុកឲ្យអ្នករាល់គ្នាហើយ ដើម្បីឲ្យអ្នករាល់គ្នាត្រាប់តាមការដែលខ្ញុំបានធ្វើឲ្យនោះ»* យ៉ូហាន ១៣:១៥។ យើងត្រូវធ្វើតាមគំរូនៃការបន្ទាបខ្លួនរបស់ព្រះអង្គ ភីលីព ២:៣-៥។ យើងត្រូវដើរតាមជំហានរបស់ទ្រង់ *«ដ្បិតទ្រង់បានហៅអ្នករាល់គ្នា មកឯសេចក្ដីនោះឯង ពីព្រោះព្រះគ្រីស្ទក៏បានរងទុក្ខជំនួសយើងដែរ ទាំងទុកដំរាប់ ឲ្យយើងរាល់គ្នាដើរតាមលំអានដាននៃទ្រង់»* ១ ពេត្រុស ២:២១។ *«តែអ្នកណាដែលកាន់តាមព្រះបន្ទូលទ្រង់វិញ នោះប្រាកដជាសេចក្ដីស្រឡាញ់នៃព្រះបានពេញខ្នាត នៅក្នុងអ្នកនោះហើយ គឺដោយសេចក្ដីនោះឯង ដែលយើងដឹងថា យើងនៅក្នុងទ្រង់ អ្នកណាដែលថាខ្លួននៅក្នុងទ្រង់ នោះត្រូវតែប្រព្រឹត្តដូចជាទ្រង់ដែរ»* ១ យ៉ូហាន ២:៥-៦។

**ការព្រមាន។** ព្រះមិនកុហកទេ ទំនុកតម្កើង ១១៩:១៦០។ ព្រះមិននាំអ្នក ឬប្រាប់អ្នក មិនឱ្យស្ដាប់បង្គាប់តាមព្រះបន្ទូលរបស់ទ្រង់ឡើយ។ ព្រះយេស៊ូវនឹងប្រទានឱ្យអ្នកដឹកនាំប្រដាប់យើង អេភេសូរ ៤:១១-១៤។ ប៉ុន្តែ ក៏មានគ្រូខុសឆ្គងជាច្រើនដែរ ១ ធីម៉ូថេ ៤:៣-៤។ សូមកុំជឿឱ្យសោះថា ព្រះប្រាប់អ្នកមិនឱ្យស្ដាប់តាមព្រះបន្ទូលរបស់ទ្រង់។ ព្រះមិនធ្វើដូច្នោះទេ។ ប្រសិនបើ អ្នកដឹកនាំពួកជំនុំប្រាប់អ្នកមិនឱ្យស្ដាប់បង្គាប់តាមព្រះបន្ទូលរបស់ព្រះ នោះគឺជាសេចក្ដីបង្រៀនខុសឆ្គងហើយ។

Khmer

**ព្រះហឫទ័យផ្ទាល់ខ្លួនរបស់ព្រះ។** ព្រះមានព្រះហឫទ័យផ្ទាល់ខ្លួនរបស់ទ្រង់សម្រាប់អ្នកជឿ ទំនុកតម្កើង ៣២:៨; សុភាសិត ៣:៥-៦ ស្តាប់បង្គាប់តាមព្រះហឫទ័យទូទៅរបស់ទ្រង់។ បន្ទាប់មក រៀនអំពីព្រះហឫទ័យផ្ទាល់ខ្លួនរបស់ទ្រង់ ចូលទូលសូមព្រះឱ្យព្រះអង្គប្រាប់អ្នក។ ស្វែងរកចម្លើយរបស់ទ្រង់នៅក្នុងព្រះបន្ទូល ប្រាជ្ញាញាណ ប្រជារាស្ត្រ និងសេចក្តីសុខសាន្តរបស់ទ្រង់។

**ទូលសូម។** អធិស្ឋានតាមសេចក្តីអធិស្ឋានរបស់ស្តេចដាវីឌ «សូមបង្ហាត់បង្រៀនឲ្យទូលបង្គំបានប្រព្រឹត្តតាមព្រះហឫទ័យទ្រង់» ទំនុកតម្កើង ១៤៣:១០។ សេចក្តីអធិស្ឋានដ៏ស្មោះត្រង់របស់អ្នកសម្រាប់ខ្លួនអ្នក និងសម្រាប់អ្នកដទៃ គឺត្រូវតែស្គាល់ និងធ្វើតាមព្រះហឫទ័យរបស់ព្រះ។

**ទទួលយកការណែនាំ។** ព្រះបានបង្ហាញព្រះហឫទ័យផ្ទាល់ខ្លួនរបស់ទ្រង់តាមរយៈព្រះបន្ទូល ប្រាជ្ញា មនុស្ស និងសេចក្តីសុខសាន្តរបស់ទ្រង់។ ចូរទូលសូមព្រះឱ្យបង្ហាញព្រះហឫទ័យទ្រង់ដល់អ្នក។ ព្រះអង្គនឹងឆ្លើយសេចក្តីអធិស្ឋានរបស់អ្នកតាមរយៈ៖

១. ព្រះបន្ទូលរបស់ទ្រង់។ ការស្គាល់ពីព្រះហឫទ័យផ្ទាល់ខ្លួនរបស់ព្រះនឹងបង្កើតទម្លាប់នៃការសិក្សាព្រះគម្ពីរ។ ព្រះហឫទ័យរបស់ព្រះសម្រាប់អ្នកនឹងបានច្បាស់ឡើងពេលអ្នកទទួលបានប្រាជ្ញា និងការយល់ដឹងចេញពីព្រះបន្ទូលរបស់ទ្រង់។ ព្រះអង្គនឹងមិននាំអ្នកឱ្យធ្វើអ្វីមួយដែលផ្ទុយពីព្រះបន្ទូលរបស់ទ្រង់ឡើយ។

២. ប្រាជ្ញារបស់ទ្រង់។ ប្រាជ្ញារបស់ព្រះចេញមកពីការស្តាប់បង្គាប់ខាងវិញ្ញាណ ១ កូរិនថូស ២:១៤-១៥។ *«កុំឲ្យត្រាប់តាមសម័យនេះឡើយ ចូរឲ្យអ្នករាល់គ្នាបានផ្លាស់ប្រែវិញ ដោយគំនិតបានកែជាថ្មីឡើង ដើម្បីនឹងអាចលមើលឲ្យបានស្គាល់បំណងព្រះហឫទ័យនៃព្រះ ដែលល្អ ស្រួលទទួល ហើយគ្រប់លក្ខណ៍ផង»* រ៉ូម ១២:២។ *សូមប្រាជ្ញាពីព្រះ «តែបើអ្នករាល់គ្នាណាមួយខ្វះប្រាជ្ញា មានតែសូមដល់ព្រះ ...នោះទ្រង់នឹងប្រទានឲ្យ»* យ៉ាកុប ១:៥។

៣. មនុស្សរបស់ទ្រង់។ មនុស្សរបស់ព្រះគឺជាប្រភពសម្រាប់ការយល់ដឹងអំពីព្រះហឫទ័យរបស់ព្រះ។ អស់អ្នកដែលបង្រៀនព្រះបន្ទូលរបស់ព្រះច្បាស់លាស់តាមរយៈការនិយាយ ឬសរសេរក្តីអាចជួយបាន កូឡុស ១:២៨។ គឺជាការល្អក្នុងការទទួលការប្រឹក្សាពីអ្នកជឿដែលពេញវ័យ។ លើសជាងនេះ ការប្រឹក្សាយោបល់គឺលើសពីគំនិតល្អ *«ទីណាគ្មានការប្រឹក្សា នោះមិនបានតាមចិត្តប៉ងទេ តែបើមានអ្នកជួយគំនិតជាច្រើន នោះនឹងកើតការវិញ»*សុភាសិត ១៥:២២។ អ្នកជឿដែលពេញវ័យមិនមែនមិនចេះភ្លាត់នោះទេ ប៉ុន្តែ ពួកគេអាចផ្តល់ឱ្យអ្នកនូវការយល់ដឹងដ៏ជ្រាលជ្រៅដើម្បីជួយអ្នកក្នុងការធ្វើតាមព្រះហឫទ័យរបស់ព្រះ។

៤. សេចក្តីសុខសាន្តរបស់ព្រះ។ សេចក្តីសុខសាន្តរបស់ព្រះគឺជាការបញ្ជាក់ចុងក្រោយនៃព្រះហឫទ័យផ្ទាល់ខ្លួនរបស់ទ្រង់ *«ចូរឲ្យសេចក្តីមេត្រីរបស់ព្រះគ្រីស្ទត្រួតត្រានៅក្នុងចិត្ត»* កូឡុស ៣:១៥។ *«យ៉ាងនោះ សេចក្តីសុខសាន្តរបស់ព្រះ ដែលហួសលើសពីអស់ទាំងគំនិត នឹងជួយការពារចិត្ត ហើយនឹងគំនិតរបស់អ្នករាល់គ្នា ក្នុងព្រះគ្រីស្ទយេស៊ូវ»* ភីលីព ៤:៧។ សេចក្តីសុខសាន្តនេះគឺព្រះជាអ្នកប្រទានមកក្នុងជម្រៅនៃសេចក្តីសុចរិតអំពីការសម្រេចចិត្តដែលតាមដោយសេចក្តីអធិស្ឋាន ការសិក្សាព្រះគម្ពីរ ប្រាជ្ញាខាងវិញ្ញាណ និងការមើលឃើញចេញពីអ្នកប្រឹក្សាយោបល់ដែលពេញវ័យខាងវិញ្ញាណ។ សូមស្វែងរក និងរង់ចាំសេចក្តីសុខសាន្តរបស់ទ្រង់។

**ធ្វើសកម្មភាព** នៅពេលអ្នកសូម ប្រសិនបើការនោះគឺជាព្រះហឫទ័យរបស់ព្រះ ទទួលចម្លើយថា «ទេ» ដូចលោកប៉ុលបានសូមដែរ ២ កូរិនថូស ១២:៧-១០។ ចម្លើយរបស់ទ្រង់ឱ្យ «រង់ចាំ» អាចជាព្រះពរដ៏ធំ អេសាយ ៤០:៣១។ នៅពេលឆ្លើយថា «បាន» ធ្វើតាមព្រះហឫទ័យទ្រង់ សូម្បីតែវាពិបាក មិនទូលំទូលាយ ឬត្រូវបង់ថ្លៃខ្ពស់ក្តី។ ពេលណាយើងរីករាយនឹងធ្វើតាមព្រះហឫទ័យរបស់ទ្រង់ចេញពីដួងចិត្តរបស់យើង ទំនុកតម្កើង ៤០:៨ អេភេសូរ ៦:៥-៦។ សូមប្រយ័ត្នជាមួយនឹងចម្លើយក្លែងក្លាយដែលបានបង្រៀនក្នុងនាមគ្រីស្ទបរិស័ទ។ ស្តាប់បង្គាប់នៅពេលអ្នកប្រាកដថា អ្នកស្គាល់ព្រះហឫទ័យរបស់ព្រះ។

---

*តើខ្ញុំស្គាល់ព្រះហឫទ័យរបស់ព្រះយ៉ាងដូចម្តេច?* © 2026 by John D. Morris III is published by Acts One Eight. អ្នកអាចបោះពុម្ព ថតចម្លង បង្ហោះ អ៊ីម៉ែល ឬផ្ញើសារ ជាមួយនឹងមាតិកាដើមដោយរួមបញ្ចូលជាមួយនឹងសេចក្តីថ្លែងការណ៍ទាំងមូល។ អ្នកអាចដាក់បញ្ចូលជាមួយឈ្មោះពន្ធកិច្ច ឬឈ្មោះពួកជំនុំ ឬផ្លាកសញ្ញារបស់អ្នកនៅលើទំព័រទីមួយ ឬអាចដាក់ព័ត៌មានទំនាក់ទំនងរបស់អ្នកនៅខាងក្រោមនៃទំព័រទីពីរ។ WillofGod316.org គឺផ្អែកលើព្រះគម្ពីរតែមួយគត់។ វាកើតមានដើម្បីជួយអ្នកជឿឱ្យស្វែងរកព្រះហឫទ័យរបស់ព្រះ។ អ្នកអាចផ្ញើអ៊ីម៉ែលទៅកាន់ Acts One Eight (ជាភាសាអង់គ្លេស ប្រសិនបើអាច) Hello@Mail316.org. សេវាកម្មបកប្រែត្រូវបានផ្តល់ជូនដោយ www.ChristianLingua.com។ *តើខ្ញុំស្គាល់ព្រះហឫទ័យរបស់ព្រះយ៉ាងដូចម្តេច?* មាន៤៨ភាសាដោយឥតគិតថ្លៃនៅលើគេហទំព័រ www.WillofGod316.org។ ការដកស្រង់ព្រះគម្ពីរជាភាសាអង់គ្លេសត្រូវបានដកស្រង់ចេញពី The Lockman Foundation′s New American Standard Bible ១៩៩៥. ការដកស្រង់ព្រះគម្ពីរជាភាសាអង់គ្លេសត្រូវបានដកស្រង់ចេញពី The Lockman Foundation′s New American Standard Bible ១៩៩៥. ការដកស្រង់ព្រះគម្ពីរភាសាខ្មែរ ចេញពីកំណែព្រះគម្ពីរបរិសុទ្ធ ១៩៥៤ (គពប)